# ការរៀបចំគំរោង

ជំហាន៖

### វិភាគស្ថានភាព

- កំនត់គំរោង
- ការវិភាគបញ្ហា
- ការវិភាគគោលបំណង

↓

### កំនត់ធាតុរបស់គំរោង

- គោលដៅ
- គោលបំណង
- សកម្មភាព

→

### កំនត់

- សូចនាករ
- មធ្យោបាយផ្ទៀងផ្ទាត់
- ការសន្មត់/កត្តាខាងក្រៅ

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.




This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.

# ការកំនត់ធាតុរបស់គំរោង

## ១. គោលដៅគំរោង (Project Goal)

វាជាឥទ្ធិពល ឬការប្រែប្រួលជាវិជ្ជមាន ទៅលើក្រុមគោលដៅ។ ជាការប្រែប្រួល លក្ខខណ្ឌ ឬស្ថាភាព របស់ក្រុមគោលដៅ ឬសហគមន៍ នាពេលអនាគត។ គំរោងមួយ មាន គោលដៅ តែមួយគត់។ គោលដៅត្រូវសរសេរជាឃ្លាបំណង (ចង់ឃើញ) ជាជាង សកម្មភាព។ ឧទាហរណ៍:

- ចំនួនគ្រោះថ្នាក់ចរាចរ ត្រូវបានកាត់បន្ថយ។
- សុខភាពកុមារនៅខេត្តសៀមរាបមានភាពប្រសើរឡើង។
- គ្រួសារប្រជាកសិករ មានសុវត្ថភាពស្បៀង។

## ២. គោលបំណងបំណង (Objectives)

ជាលទ្ធផលដែលគំរោងនឹងធ្វើអោយសំរេច។ គំរោងមួយ មានគោលបំណងច្រើន ដែលរួម ចំណែកទៅសំរេចគោលដៅ។ គោលបំណង គួរសរសេរជាលទ្ធផលចង់បាន ជាជាង ដំណើរការ។ គោលបំណង គួរមានភាពពិតប្រាកដ។ ឧទាហរណ៍:

- ប្រព័ន្ធសុវត្ថភាពផ្លូវត្រូវបានកែលំអរ ។
- កុមារយល់ដឹង និងប្រកាន់ខ្ជាប់នូវវិធានការសុខភាពអនាម័យមូលដ្ឋាន។
- គ្រួសារកសិករមានទំនុកចិត្ត បានអនុវត្តការដាំដុះ និងចិញ្ចឹមសត្វដោយជោគជ័យ។

## ៣. សកម្មភាព (Strategies/Activties)

ជាដំណើរការ ឬទង្វើរ ដើម្បីប្រែក្លាយធនធាន ឈានទៅសំរេចគោលបំណង។ មាន សកម្មភាពច្រើនរួមគ្នា សំរេចគោលបំណងមួយ។ សកម្មភាពត្រូវសរសេរជា អំពើ (ប្រើ កិរិយាស័ព្ទ)។ ឧទាហរណ៍:

- ដាក់ផ្លាកសញ្ញាលើផ្លូវអោយបានគ្រប់គ្រាន់។
- បើកវគ្គបណ្តុះបណ្តាលអំពីសុខភាពដល់កុមារ
- បណ្តុះបណ្តាលបច្ចេកទេសកសិកម្មទំនើបដល់ប្រជាកសិករ។

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.